ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅប្រទេសជប៉ុន ជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍ ដល់ស្ត្រីខ្មែររងគ្រោះចំនួន៧នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ជប៉ុន** សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្ត Gunma ប្រទេសជប៉ុន បានជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍ដល់ស្ត្រីខ្មែរចំនួន**៧នាក់** ដែលរងគ្រោះដោយការជួញដូរផ្លូវភេទ ក្រោយពីមានការផ្តល់ព័ត៌មានផ្ទាល់ពីស្ត្រីរងគ្រោះទៅកាន់ទំព័រហ្វេសប៊ុករបស់ស្ថានទូត។

ស្ត្រីរងគ្រោះទាំង**៧នាក់** (២នាក់មកពីភ្នំពេញ ២នាក់ពីខេត្តព្រៃវែង ម្នាក់ពីខេត្តពោធិ៍សាត់ ម្នាក់ពីខេត្តកំពង់ស្ពឺ និងម្នាក់ទៀតពីខេត្តតាកែវ) ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅដល់ប្រទេសជប៉ុន កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការរៀបចំឯកសារសុំទិដ្ឋាការ និងសំបុត្រយន្តហោះ ពីបុរសជនជាតិជប៉ុនម្នាក់ ដែលជាម្ចាស់ភោជនីយដ្ឋានមួយនៅក្នុងខេត្ត Gunma ។ បុរសនោះ បានសន្យាផ្តល់ការងារធ្វើនៅភោជនីយដ្ឋានរបស់ខ្លួន ដល់ស្ត្រីរងគ្រោះជាមួយនឹងប្រាក់ខែខ្ពស់ តែផ្ទុយទៅវិញ បានគំរាមកំហែង និងបង្ខំអោយស្ត្រីរងគ្រោះ បំរើសេវាផ្លូវភេទដល់ភ្ញៀវនៅភោជនីយដ្ឋានទៅវិញ និងមិនបានផ្តល់ប្រាក់បៀវត្សឡើយ។

ភ្លាមៗ បន្ទាប់ពីទទួលបានសំណើពីសាម៉ីខ្លួន ស្ថានទូតបានអន្តរាគមន៍ជួយស្ត្រីរងគ្រោះទាំង**៧នាក់** និងនាំពួកគេទៅស្នាក់នៅស្ថានទូតជាបណ្តោះអាសន្ន ដោយផ្តល់អាហារបរិភោគ សេវាថែទាំសុខភាព និងសម្ភារៈប្រើប្រាស់ចាំបាច់ដទៃទៀតផងដែរ។

ស្ថានទូតក៏បានបំពេញកិច្ចការមួយចំនួនទៀត ដើម្បីការពារប្រយោជន៍ដល់ស្ត្រីរងគ្រោះ ដូចជា៖

- សហការជាមួយនគរបាលខេត្ត Gunma សាកសួរព័ត៌មានពីស្ត្រីរងគ្រោះ ដើម្បីរៀបចំសំណុំឯកសារបញ្ជូនទៅតុលាការ និងស្វែងរកជនសង្ស័យនិងអ្នកពាក់ព័ន្ធ មកផ្តន្ទាទោសតាមច្បាប់។
- ស្វែងរកក្រុមមេធាវីស្ម័គ្រចិត្ត ដើម្បីប្តឹងទៅតុលាការ ជួយទាមទារប្រាក់ខែដែលជនសង្ស័យសន្យាផ្តល់អោយ និងទាមទារប្រាក់ជំងឺចិត្តជូនស្ត្រីរងគ្រោះ។

- ស្នើសុំអោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ជួយដោះស្រាយសំបុត្រយន្តហោះជូនស្ត្រីរងគ្រោះទាំង៧នាក់ និងបន្តគាំពារពួកគេពេលមកត្រឡប់មកដល់កម្ពុជាវិញ។ IOM បាន ឯកភាពតាមសំណូមពររបស់ស្ថានទូត។

ដោយសារបញ្ហាសុខភាព ស្ត្រីរងគ្រោះម្នាក់ បានស្នើសុំត្រឡប់មកកម្ពុជាមុន ហើយបានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** កាលពីថ្ងៃទី**២៧ ខែធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង**១៩:៣៥**នាទី។

ដោយឡែក ស្ត្រីរងគ្រោះ៦នាក់ផ្សេងទៀត នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៩ ខែមករា ឆ្នាំ២០១៧** វេលាម៉ោង**១៩:៣៥** នាទី ក្រោយបញ្ចប់ការសាកសួរពីសំណាក់អាជ្ញាធរខេត្ត Gunma មន្ត្រីអន្តោប្រវេសន៍ ក្រុមមេធាវី និងមន្ត្រីអង្គការIOM ៕

ភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ